ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣៣៣

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ២០០ សជណ ធទឧ

# សេចក្តីជូនដំណឹងបន្ថែម
## ស្តីពីស្ថានភាពទឹកជំនន់ទន្លេមេគង្គ

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងបន្ថែមដល់សាធារណជនឱ្យបានជ្រាបថា បន្ទាប់ពីបានធ្វើការជូនដំណឹងលើកទី 1 កាលពីថ្ងៃទី 01 ខែសីហា ឆ្នាំ 2011 រួចមក ក្រសួងសង្កេតឃើញថា ស្ថានភាពទឹកជំនន់ទន្លេមេគង្គនៅតែបន្តកើនឡើងជាលំដាប់ ពិសេស ក្នុងខេត្តស្ទឹងត្រែង និងខេត្តក្រចេះ ។ កម្ពស់ទឹកនៅតាមស្ថានីយជលសាស្ត្រស្ទឹងត្រែង និងក្រចេះ នាវេលាម៉ោង 07 h 00 ព្រឹក ថ្ងៃទី 08 ខែសីហា ឆ្នាំ 2011 មាន :

- ខេត្តស្ទឹងត្រែង ទឹកមានកម្ពស់ 10,00 m ទាបជាងកម្រិតកម្ពស់ប្រុងប្រយ័ត្ន 0,70 m ។
- ខេត្តក្រចេះ ទឹកមានកម្ពស់ 20,12 m ទាបជាងកម្រិតកម្ពស់ប្រុងប្រយ័ត្ន 1,88 m ។

យោងតាមការពិនិត្យ តាមដានយ៉ាងយកចិត្តទុកដាក់ យើងអាចព្យាករបានថា :

- ថ្ងៃទី 12 ខែសីហា ឆ្នាំ 2011 ទឹកទន្លេមេគង្គនៅខេត្តស្ទឹងត្រែង អាចនឹងឡើងដល់កម្ពស់ 11,30 m ។
- ថ្ងៃទី 13 ខែសីហា ឆ្នាំ 2011 ទឹកទន្លេមេគង្គនៅខេត្តក្រចេះ អាចនឹងឡើងដល់កម្ពស់ 21,90 m ។

ដោយឡែកកម្ពស់ទឹកជំនន់នៅទន្លេមេគង្គភាគខាងក្រោម ទន្លេបាសាក់ និងទន្លេសាប ក៏នឹងបន្តហក់ឡើងជាបន្តបន្ទាប់ផងដែរ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលរស់នៅតាមដងទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ សូមបង្កើនការយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់ចំពោះស្ថានភាពទឹកជំនន់ខាងលើនេះ ដើម្បីចៀសវាងនូវរាល់គ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានជាយថាហេតុ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែសីហា ឆ្នាំ ២០១១

រដ្ឋមន្ត្រី

លឹម គានហោ

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh